**<u>កម្មវត្ថុ៖ ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន – កិច្ចប្រជុំផ្ទាល់ ដោយមានជម្រើសតាមអនឡាញ – ថ្ងៃទី 12 ខែកុម្ភៈ ឆ្នាំ 2026</u>**

ភាគីពាក់ព័ន្ធយុត្តិធម៌បរិស្ថានទាំងអស់ជាទីគោរព!

ការិយាល័យប្រតិបត្តិកិច្ចការថាមពលនិងបរិស្ថាន (EEA) សូមគោរពអញ្ជើញក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន (EJC) ដើម្បីចូលរួមក្នុងកិច្ចប្រជុំបន្ទាប់របស់ខ្លួននៅ**ថ្ងៃទី 12 ខែកុម្ភៈ ឆ្នាំ 2026 វេលាម៉ោង 6:30 ល្ងាច (ម៉ោងស្តង់ដាខាងកើត)។** សមាជិកក្រុមប្រឹក្សានឹងពិភាក្សាអំពីរបៀបវារៈនៃការប្រើប្រាស់ថាមពល។ ពេលវេលាកំណត់នៅក្នុងកិច្ចប្រជុំនឹងត្រូវបានផ្តល់ជូនសាធារណជនដើម្បីចែករំលែកមតិយោបល់។

**សូមចុះឈ្មោះសម្រាប់កិច្ចប្រជុំតាមរយៈតំណភ្ជាប់នេះ៖**
**https://www.zoomgov.com/webinar/register/WN_rZw77ziCTN-ihFdsoPHvmA**

**ការរៀបចំកិច្ចប្រជុំ៖** កិច្ចប្រជុំទម្រង់កូនកាត់នេះនឹងត្រូវបានរៀបចំទាំងតាមអនឡាញនៅលើ Zoom និងដោយផ្ទាល់នៅសាលា Roxbury Community College ។ កិច្ចប្រជុំនេះត្រូវបានប៉ាន់ស្មានថាមានរយៈពេល 60 នាទី។ អគារប្រជុំមានទីតាំងស្ថិតនៅ 1234 Columbus Ave, Roxbury Crossing MA 021210 ។ អាចធ្វើដំណើរទៅដល់បានតាមរយៈ ខ្សែរថភ្លើងពណ៌ទឹកក្រូច (Orange Line) ឆ្ពោះទៅកាន់ Forest Hills (ចុះនៅស្ថានីយ Roxbury Crossing) និងរថយន្តក្រុងលេខ 14, 22, 41 និង 66។ សម្រាប់ភ្ញៀវ មានចំណតរថយន្តផ្តល់ជូននៅចំណតលេខ 2 (Parking Lot #2)។

**ជំនួយផ្នែកបកប្រែ៖** ការបកប្រែផ្ទាល់មាត់តាមអនឡាញ រួមមាន ភាសាអេស្ប៉ាញ ព័រទុយហ្គាល់ប្រេស៊ីល ចិនកុកងឺ វៀតណាម ក្រេអូលហៃទី ភាសា Cape Verdean Creole និងភាសាសញ្ញាអាមេរិក (ASL)។ នឹងមានការផ្តល់ជូនអ្នកបកប្រែផ្ទាល់មាត់សម្រាប់ភាសាអេស្ប៉ាញ ភាសាព័រទុយហ្គាល់ប្រេស៊ីល និងភាសាហៃទីក្រេអូល ។ ប្រសិនបើអ្នកត្រូវការការបកប្រែផ្ទាល់មាត់ជាភាសាជាក់លាក់ ឬការសម្របសម្រួលបន្ថែមណាមួយ សូមបញ្ជូលសំណើនោះក្នុងអ៊ីមែលទៅកាន់ meetings@erg.com។ សំណើត្រូវតែដាក់ជូនរយៈពេល 48 ម៉ោងមុនពេលកិច្ចប្រជុំចាប់ផ្តើម។ ដើម្បីទទួលបានព័ត៌មាននេះជាភាសាអង់គ្លេសអក្សរពុម្ពធំ ឬអក្សរស្ទាបសម្រាប់មនុស្សពិការភ្នែក សូមហៅទូរសព្ទទៅលេខ 1-877-623-6765 ។ TTY៖ 1877-623-7773។

**ច្បាប់ប្រជុំដោយបើកចំហ៖** ក្រុមប្រឹក្សា EJ ប្រតិបត្តិការក្រោមច្បាប់ប្រជុំដោយបើកចំហ [https://www.mass.gov/the-open-meeting-law] ហើយស្វាគមន៍សមាជិកសាធារណជនទាំងអស់ដែលមានបំណងចង់ចូលរួមសង្កេតកិច្ចប្រជុំបើកផ្លូវការរបស់ខ្លួន។ ក្នុងអំឡុងពេលប្រជុំនេះ អ្នកសង្កេតការណ៍អាចបញ្ចេញមតិ ឬសួរទៅក្រុមប្រឹក្សា EJ ដោយមានការអនុញ្ញាតពីប្រធានអង្គប្រជុំ។

**ព័ត៌មានបន្ថែមអំពីក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន (EJC)៖** EJC ត្រូវបានតែងតាំងដោយអភិបាលដើម្បីផ្តល់យោបល់ និងផ្តល់អនុសាសន៍ដល់រដ្ឋមន្ត្រី EEA អំពីគោលនយោបាយ និងស្តង់ដាដែលពាក់ព័ន្ធ ដើម្បីសម្រេចបាននូវគោលការណ៍យុត្តិធម៌បរិស្ថាននានា។ គោលការណ៍ទាំងនេះត្រូវបានកំណត់ដោយច្បាប់របស់រដ្ឋថាជា "គោលការណ៍ដែលគាំទ្រការការពារពីការបំពុលបរិស្ថាន និងលទ្ធភាពក្នុងការរស់នៅក្នុងបរិស្ថានស្អាត និងមានសុខភាពល្អ ដោយមិនគិតពីពូជសាសន៍ ពណ៌សម្បុរ ប្រាក់ចំណូល វណ្ណៈ ពិការភាព អត្តសញ្ញាណយេនឌ័រ ទំនោរផ្លូវភេទ ដើមកំណើតជាតិ ជាតិសាសន៍ ឬពូជពង្ស ជំនឿសាសនា ឬជំនាញភាសាអង់គ្លេស ដែលរួមមាន៖ (i) ការចូលរួមយ៉ាងសកម្មរបស់ប្រជាជនទាំងអស់ពាក់ព័ន្ធនឹងការអភិវឌ្ឍ ការអនុវត្ត និងការពង្រឹងការអនុវត្តច្បាប់ បទបញ្ញត្តិ និងគោលនយោបាយបរិស្ថាន ដោយរួមទាំងគោលនយោបាយស្តីពីបម្រែបម្រួលអាកាសធាតុ និង (ii) បំណែងចែកប្រកបដោយសមធម៌នូវថាមពលនិងផលប្រយោជន៍បរិស្ថាន

ព្រមទាំងបន្ទុកបរិស្ថាន។” ច្បាប់នេះត្រូវបានចែងត្រង់ផ្នែក 62L ក្នុងតំណនេះ៖ [https://malegislature.gov/Laws/SessionLaws/Acts/2021/Chapter8]។

ព័ត៌មានបន្ថែមអំពី EJC របៀបវារៈនៃកិច្ចប្រជុំនាពេលខាងមុខ និងរបាយការណ៍កិច្ចប្រជុំកន្លងមក អាចរកបាននៅទីនេះ៖ https://www.mass.gov/orgs/environmental-justice-council។ សូមចុចលើពាក្យ “Select Language” នៅខាងលើផ្នែកខាងស្តាំនៃគេហទំព័រ ដើម្បីបកប្រែទំព័រនេះ។

សូមអរគុណ!

María Belén Power
អនុរដ្ឋមន្ត្រីសមធម៌និងយុត្តិធម៌បរិស្ថាន
ការិយាល័យប្រតិបត្តិកិច្ចការថាមពលនិងបរិស្ថាន